# ការសម្ភាសរបស់អ៊ុំស្រី ជុំ ផាវើយ

**កៈ អ្នកសម្ភាសឈ្មោះ លន់ មុណាក់** **ខៈ អ្នកដែលត្រូវគេសម្ភាសឈ្មោះ ជុំ ផាវើយ**

## ពត៍មានសង្ខេបរបស់ អ៊ុំស្រី ជុំ ផាវើយៈ

អ៊ុំស្រី ជុំផាវើយៈ មានទីលំនៅបច្ចុប្បន្ននៅប្រទេសកម្ពុជា ខេត្តបាត់ដំបង នៅភូមិអូរដំបង ឃុំអូរដំបងពីរ ស្រុក សង្កែ ខេត្ត បាត់ដំបង។ ហើយនៅក្នុងគ្រុមគ្រួសាររបស់អ៊ុំស្រី អ៊ុំស្រីមានបងប្អូន(ចំនួនដប់នាក់) ហើយអ៊ុំជាកូនពៅ។ ហើយបងប្អូនរបស់អ៊ុំភាគច្រើនបានស្លាប់នៅជំនាន់សម័យប៉ុលពត។ ហើយសព្វថ្ងៃនេះនៅរស់តែអ៊ុំហើយនឹងបងស្រី។ ហើយ អ៊ុំស្រីបានរៀបការនៅឆ្នាំ (១៩៨៥) ហើយក្រោយពីរៀបការអ៊ុំមានកូនចំនួនបីនាក់។ ហើយឥឡូវនេះពួកគាត់មានគ្រុមគ្រួសារអស់ហើយ។ ហើយសព្វថ្ងៃនេះអ៊ុំរស់នៅជាមួយនឹងកូនៗរបស់អ៊ុំដោយសារតែប្តីរបស់អ៊ុំបានស្លាប់នៅពេលដែលកូនរបស់គាត់នៅតូច។

កៈ ជាដំបូងខ្ញុំសូមជំរាបសួរអ៊ុំ!

ខៈ ចាស! ជំរាបសួរ។

កៈ ចាស! អញ្ចឹងគេបានអញ្ជើញខ្ញុំមកធ្វើការសម្ភាសអ៊ុំនៅថ្ងៃនេះ។

ខៈ ចាស

កៈ ចាស! អញ្ចឹងគម្រោងមួយនឹងគឺមកពីសាលាប៊ីវាយយូប្រ៊ូវ៉ូយូថាស៍។

ខៈ អញ្ចឹង។

កៈ ចាស! ហើយសាលាមួយនឹងគឺនៅសហរដ្ឋអាមេរិចទេ ប៉ុន្តែគេបានអញ្ជើញខ្ញុំមកនៅថ្ងៃនេះ ដម្បីធ្វើការសម្ភាសពួកគាត់ពីជីវៈប្រវត្តិរបស់ពួកគាត់។

ខៈ ចាសនឹងហើយ!

កៈ ហើយតើអ៊ុំបានឆ្លងកាត់នៅការលំបានអ្វីខ្លះតាំងពីក្មេងមករហូតមកដល់ប៉ុននេះ? ហើយពីជីវិតរបស់អ៊ុំស្រីពីកាលនៅជំនាន់សម័យប៉ុលពតផងដែល។

ខៈ ចាស!

កៈ អញ្ចឹងខ្ញុមសូមធ្វើការសម្ភាសហើយសួរពីមួយនឹងខ្លះនៅថ្ងៃនេះ។ ហើយខ្ញុំអ្នកសម្ភាសថ្ងៃនេះនាងខ្ញុំឈ្មោះ លន់មុណាក់ ហើយថ្ងៃនេះជាថ្ងៃទី ២៩ ខែ ០៥ ឆ្នាំ២០២០។ អញ្ចឹងតើអ៊ុំស្រីមានឈ្មោះអ្វីដែល???

ខៈ ខ្ញុំឈ្មោះ ជុំ ផារើយ។

កៈ ??

ខៈ ជុំ ផារើយ។

កៈ ចាស! ឈ្មោះរបស់អ៊ុំពិរោះម្ល៉េះ??

ខៈ ហាហា! ចាសជុំផារើយ។

កៈ ចាសអ៊ុំ! អញ្ចឹងតើអ៊ុំមានឈ្មោះក្រៅអីផ្សេងពីនឹងទៀតដែលឬទេអ៊ុំ???

ខៈ អត់ទឹអត់មានទេ។

កៈ អត់មានទេណ៎អ៊ុំ??

ខៈ ចាសចាសអត់អត់ទេ!

កៈ អញ្ចឹងតាំងពីក្មេងមកនៅដដែលណ៎អ៊ុំ???

ខៈ ចាសនឹងនឹងហើយ។

កៈ ចាសនឹងហើយ! អញ្ចឹងតើឥឡូវនេះតើអ៊ុំស្រីមានអាយុប៉ុន្មានហើយ???

ខៈ ឥឡូវនេះអ៊ុំមានអាយុ ៥៩ ឆ្នាំហើយ។

កៈ អូ!! អ៊ុំនៅក្មេង។

ខ៖ ចាស!

ក៖ អ៊ុំ ៥៩??

ខ៖ អ៊ុំ ៥៩ ឆ្នាំហើយ!

ក៖ ចាស! អញ្ចឹងតើអ៊ុំស្រីមានចាំថ្ងៃខែឆ្នាំកំណើតដែលអ៊ុំបានកើតដែលឬទេ???

ខ៖ អ៊ុំកើតនៅឆ្នាំ ៦២ អូ...ឆ្នាំ ៦៣( ១៩៦៣ )។

ក៖ ចាសអ៊ុំ!

ខ៖ ១៩៦៣។

ក៖ ចាស! អញ្ចឹងតើអ៊ុំមានចាំដូចជាខែ១១ឬក៏ខែណាដែលអ៊ុំ???

ខ៖ ខែ..ខែ១១។ ខែ ១១មែន។

ក៖ អូ្ហ!!! ខែ១១មែន??

ខ៖ ចាសនឹងហើយ!។

ក៖ ដោយសារតែខ្ញុំកើតនៅខែ១១ដែលបានជាខ្ញុំយកខែ១១មិញ។

ខ៖ ចាសនឹងហើយ!

ក៖ អញ្ចឹងតើថ្ងៃណាដែលអ៊ុំ???

ខ៖ ថ្ងៃច័ន្ទ។

ក៖ ដូចជាថ្ងៃទីប្រាំឬក៏ថ្ងៃទីប្រាំមួយដែលអ៊ុំ???

ខ៖ អូ្ហ!!! ថ្ងៃទីពីរ។

ក៖ ថ្ងៃទីពីរហូអ៊ុំ??

ខ៖ ចាស

កៈ អ៊ូ!! ឈិតគ្នាទៀត។

ខៈ ចាស!

កៈ ចាសអញ្ចឹងតើអ៊ុំមានចាំទីកន្លែងកំណើតរបស់អ៊ុំដែលឬទេ???

ខៈ នេះអ៊ុំកើតនៅទីនេះឯង! នៅនឹងអូរដំបងនេះ។

កៈ នៅភូមិអូរដំបងពីរ?

ខៈ ចាស! នៅភូមិអីរដំបងពីរ។

កៈ ចាស! អញ្ចឹងផ្ទះនេះអ៊ុំនៅតាំងពីអ៊ុំនៅក្មេងមកឬក៏ម៉េចដែលអ៊ុំ???

ខ៖ អត់ទេនៅពីក្មេងផ្ទះក្បឿងធំណាស់!!! ផ្ទះក្បឿងធំណាស់។

កៈ អ៊ូ!!!

ខៈ ប៉ុន្តែជំនាន់ប៉ុលពតអីរបាត់។

កៈ ចាស!

ខៈ ប៉ុន្តែអីរចូលមកធ្វើខ្លួនឯង។

កៈ ចាស! អញ្ចឹងមានន័យថាអ៊ុំជាអ្នកមានហើយសម័យនឹងមានដែលឬទេអ៊ុំ???ខ

ខៈ ចាស! ពីសម័យសង្គមហះ???

កៈ ចាសអ៊ុំ!!

ខៈ ពីសង្គមពុកម៉ែគាត់មានមែន។ ធ្វើស្រែចំការមែនប៉ុន្តែមាន។

កៈ ចាសនឹងហើយអ៊ុំ!

ខៈ ចាស!

កៈ ចាស! អញ្ចឹងប៉ុលពតបានរំលាយផ្ទះរបស់អ៊ុំចោល??

ខ៖ ចាសនឹងហើយអើរកំទេចចោល។

ក៖ ចាសនឹហហើយអ៊ុំ, សេដមែនទែន។

ខ៖ ចាស!

ក៖ ចាសអញ្ចឹង! តើអ៊ុំមានចាំថ្ងៃខែហើយនឹងឆ្នាំដែលអ៊ុំបានរៀបការទេ???

ខ៖ រៀបការហ្ស???

ក៖ ចាសអ៊ុំ!

ខ៖ រៀបការនៅឆ្នាំ ១៩៨៥។

ក៖ ចាសអ៊ុំ!

ខ៖ នឹងហើយនៅឆ្នាំ ១៩៨៥។

ក៖ ជាសមុនសង្គម..ក្រោយ???

ខ៖ អត់ទេក្រោយក្រោយ។

ក៖ អ្វូចាសនឹងហើយក្រោយ! ត្រូវហើយអ៊ុំខ្ញុំច្រឡំ។ នៅឆ្នាំ១៩៧០ជាងនឹងប៉ុលពតទេ។

ខ៖ ចាសចាសនឹងហើយ។

ក៖ ចាសចាសនឹងហើយអ៊ុំ។

ខ៖ នឹងហើយរៀបការនៅឆ្នាំ១៩៨៥។

ក៖ ចាស! អញ្ចឹងតើអ៊ុំអាចប្រាប់ខ្ញុំបានដែឡប្ញទេពីប្រវត្តិសេហ្នារបស់អ៊ុំ? ធ្វើម៉េចបានអ៊ុំបានជួបជាមួយនឹងអ៊ុំប្រុស?? ហើយបានបានឈានចូលដល់ការរៀបការ???

ខ៖ ជួបអ៊ុំប្រុស! ដោយសារតែអ៊ុំប្រុសឃើញអ៊ុំនៅម្នាក់ឯងអត់មានឪពុកម្តាយពួកគាត់ស្លាប់ចោលអស់។

ក៖ ចាសអ៊ុំ!

ខ៖ ហើយអាណិតទៅ!

ក៖ ចាសអ៊ុំ!

ខ៖ ហើយអាណិតទៅ, ហើយគាត់ជាបងប្អូនឯងដែល។ ត្រូវជាបងប្អូនជីដូនមួយ។

ក៖ អូ្ហ!!!

ខ៖ អញ្ចឹងដល់ពេលឃើញអាណិតក៏ចូលមកដណ្ដឹងៗការទៅ។

ក៖ ចាសចាស!

ខ៖ ចាសនឹងហើយ!

ក៖ អញ្ចឹងអ៊ុំកាលនឹងស្រឡាំញ់គ្នាទៅវិញទៅមកដែគតើហី???

ខ៖ នឹងហើយ។ ស្រឡាញ់គ្នាទៅវិញទៅមកដែលតើមានអី។

ក៖ ចាសាចាសខ្ញុមស្មានតែ..!!

ខ៖ និយាយគ្នារាល់តែថ្ងៃនឹងមានអី។

ក៖ ហាហា!!!

ខ៖ ហាហាហា!

ក៖ ហើយក៏មានចិត្តលើគ្នាហើយក៏អ៊ុំប្រុសចូលមកដណ្ដឹងអ៊ុំទៅ???

ខ៖ ចាសនឹងហើយ។ ហើយក៏ចូលមកដណ្ដឹងអ៊ុំទៅ។

ក៖ ចាសអឹម...! ល្អមែនទែន៕ អញ្ចឹងមានតែប៉ុនណឹងតើហីអ៊ុំ???

ខ៖ ចាស! មានទេប៉ុននឹងឯង។

ក៖ ចាសអញ្ចឹងតើប្រើរយៈពេលប៉ុន្មានខែហើយប៉ុន្មានឆ្នាំដែលអ៊ុំ???

ខ៖ គេទាក់ទងចូលមកដណ្ដឹងតែរយៈពេលបីខែបានការ។

កៈ អ៊ូ!!! លឿងមែនទែនអ៊ុំ៕

ខៈ ចាសនឹងហើយ!៕

កៈ ឡើលងលឿនជាងក្មេងសម័យនេះទៅទៀត។

ខៈ ចាសនឹងហើយ! លឿនហាសហាហា។

កៈ ហាហា!

ខៈ តែបីខែរៀបការហើយ។

កៈ ចាសអ៊ុំ! អញ្ចឹងនៅក្នុងសមាជិកគ្រុមគ្រួសាររបស់អ៊ុំតើអ៊ុំមានបងប្អូនប៉ុន្មានអ្នកដែល???

ខៈ នៅក្នុងសមាជិកគ្រួសារខ្ញុំ ខ្ញុំមានប្រាំបួននាក់។

កៈ អ៊ូយ!!! ច្រើនមែណទែនអ៊ុំ៕

ខៈ ចាសច្រើននឹងហើយ! ហើយខ្ញុំពៅគេ៕

កៈ ហើយពៅគេទៀត???

ខៈ ចាសពៅគេ! អញ្ចឹងបងបងរបស់អ៊ុំបង្គស់គាត់មានអាយុប៉ុន្មានទៅអញ្ចឹង???

ខៈ អ៊ូ!!! បើសិនជគាត់នៅ អាយុ៨០សិបជាងហើយគាត់ឆ្នាំថ្មាស់។

កៈ ចាសអ៊ុំ!

ខៈ ៨០ ហើយ ៨២៨៣ហើយ។

កៈ ចាសនឹងហើយអ៊ុំ។ អញ្ចឹងមានន័យថាគាត់ស្លាប់ហើយមែនទេអ៊ុំ???

ខៈ ចាស! ស្លាប់ហើយ, ស្លាប់ទាំងអស់! ហើយសព្វថ្ងៃនេះនៅតែពីរនាក់បង! ហើយម៉ែរុងរឿង
គាត់ទៅនៅ។ ម៉ែកាវ៉ាន់នេះ!?

កៈ អូចាស!

ខ៖ នៅតែពីរនាក់នឹងឯង។ ហើយក្រៅពីនឹងទៀតស្លាប់ទាំងអស់ហើយ។

ក៖ ចាសនឹងហើយអ៊ុំ! អញ្ចឹងដោយសារតែអ៊ុំមានបងប្អូនប្រាំបួននាក់អញ្ចឹងហាស់!!

ខ៖ ចាស!

ក៖ ហើយបើតាមដែលអ៊ុំបានប្រាប់មកខ្ញុំអ៊ុំមានអាយុរៀងច្រើនដែលហើយ៕

ខ៖ ចាសនឹងហើយ។

ក៖ អញ្ចឹងតើបងប្អូនរបស់អ៊ុំពួកគាត់ស្លាប់អស់ប៉ុន្មានអ្នកហើយនៅក្នុងចំនោមប្រាំបួននាកើនឹង???

ខ៖ បងប្អូនរបស់ខ្ញុំស្លាប់អស់ប្រាំពីរហើយ។

ក៖ អ៊ូស!!! ច្រើនណាស់អ៊ុំ។

ខ៖ ចាសនឹងហើយស្លាប់អស់ប្រាំពីរនាក់ហើយ។ នៅតែបីរនាក់ទេ។ ហើយស្លាប់នៅជំនាន់ប៉ុលពតអស់ប្រាំ។

ក៖ អ៊ូយ!!!

ខ៖ ហើយ,នឹងហើយស្លាប់នៅជំនាន់ប៉ុលពតអស់ប្រាំ។

ក៖ ចាសអ៊ុំ!

ខ៖ ហើយស្លាប់នៅនេះសម័យនេះអស់បីនាក់ទៀត។

ក៖ ចាសអ៊ុំ! ប្រាំនឹងប្រាំបីវាអស់ប្រាំបីហើយ។ អញ្ចឹងនៅសល់តែពីរទៀត!?

ខ៖ ចាសនឹងហើយនៅសល់ពីរ។ ទាំងអស់វាដប់មែននឹងឯង។ ប៉ុន្តែវាខូចលង់ទឹមអស់មួយ។

ក៖ អ៊ូ!!!

ខ៖ នឹងហើយ!

ក៖ កុំអីដប់នាក់អ្នកហើយ។

ខ៖ នឹងហើយកុំអីដប់នាក់។

ក៖ ចាស! ថាដប់ចុះព្រោះអីគាត់លង់ទឹក។

ខ៖ ចាស! ដប់មែន។

ក៖ ចាសបើគាត់បានកើតមកហើយ។

ខ៖ ចាសនឹងហើយ!

ក៖ ចាសដប់នាក់។

ខ៖ ចាស!

ក៖ ចាស! អញ្ចឹងនៅកូនពៅគឺអ៊ុំ?!! ហាហា

ខ៖ ចាសហាហា..នៅកូនពៅ។

ក៖ ចាស! អញ្ចឹងបងប្អូនរបស់អ៊ុំទាំងប្រាំពីរប្រាំបីនាក់ដែលពួកគាត់បានស្លាប់នឹងតើពួកគាត់បានធ្វើអ្វីខុសដែលបានជាគេសម្លាប់ពួកគាត់???

ខ៖ អូ!! អត់ទេ.. ពួកគាត់ធ្វើទាហាន។

ក៖ អូ!!!

ខ៖ នឹងហើយ! ហើយដូចថារកស៊ីទៅវាមានអញ្ចឹងហើយប៉ុលពតនឹងគេច្រណែននិនទាចាក់ចុកគ្នាយកទៅអស់ទៅណាស់។

ក៖ អូ!!! អញ្ចឹងទៀត???

ខ៖ ចាសនឹងហើយ។

ក៖ អញ្ចឹងសម័យនឹងគេច្រណែនគ្នាពេលដែលឃើញយើងមានបាន???

ខ៖ នឹងហើយ! នឹងហើយ។ ពេលសង្គមពេលដែលយើងមានបាននឹងគេចូលយកទៅប៉ុលពតគេវាយតម្លៃយើងថាយើងមានបាន។ តែថាយើងជាអ្នកមានមេទ័ពសកដិភូមិអីចឹងហាស់???

កៈ ចាសអ៊ុំ!

ខៈ រួចទៅវាចាប់ចងយើង យកទៅសម្លាប់បោលទៅណាស់។

កៈ អ៊ូ!!! ស្តាយមែនទែនអ៊ុំ៕

ខៈ ចាសចាសនឹងហើយ។

កៈ ហើយបើសិនជាយើងទៅធ្វើអ្វីខុសហើយគេយកយើងទៅសម្លាប់ចោលមួយនឹងយើងអត់សូវខឹងទេណាស់អ៊ុំ៕

ខៈ នឹងហើយនឹងហើយ! ចុះកាលនឹងសុទ្ធតែអញ្ចឹងឯង។

កៈ ចាសចាស !

ខៈ ចាប់យកទៅ។

កៈ ហ៊ឹម...! ហើយអ្នកដែឡចាប់ទៅនឹងជាអន្ទភូមិអ្នកដែលយើងធ្លាប់ស្គាល់ពីមុនមកទៀត???

ខៈ ចាស! អ្នកដែលស្គាល់នឹងឯង។

កៈ ចាសអ៊ុំ! អញ្ចឹងអ្នកអស់នឹងក៏ប្រហែលទៅអស់ហើយដែលន៍អ៊ុំ???

ខៈ ចាសទៅអស់ដែលហើយ។

កៈ ចាសអ៊ុំ!

ខៈ នឹងហើយហាហា!

កៈ នឹងហើយ! បានជាគេថាបាប។

ខៈ នឹងហើយ។

កៈ ចាស! ស្តាយមែនទែនអ៊ុំ។ តាមដែលខ្ញុំធ្លាប់បានសម្ភាសចាស់ៗកន្លងមក, បងប្អូនរបស់គសត់ដែលបនយកទៅសម្លាប់ដូចថាពួកគាត់លួចរបស់គែអីគែអញ្ចឹងហាស់អ៊ុំ!? តែនេះអត់ទេគឺពួកគាត់ត្រូវបានគែសម្លាប់ដោយសារតែលការច្រនែនឈ្មាននីស។

ខ៖ ចាសអត់ទេ!  ដោយសារតែការច្រណែនឈ្នានីសនិនទា ឃើញយើងមាន។

ក៖ ចាសនឹងហើយអ៊ុំ។

ខ៖ ដោយសារតែយើងមាន។

ក៖ ចាសាចាស! ចុះពីមុនអ៊ុំនៅសង្គមដោយសារតែផ្ទះរបស់អ៊ុំក្បឿងហើយធំអញ្ចឹងហាស់៕

ខ៖ ចាសនឹងហើយ!ក្បឿងធំ។ ធំហើយគាត់បានគាត់បានអោយកូនគាត់ធ្វើការទាំងអស់នឹង។

ក៖ ចាសនឹងហើយអ៊ុំ។

ខ៖ នឹងហើយ!

ក៖ ស្គាយមែនទែនបើសិនជាំនៅបងប្អូនជុំគ្នាច្រើនហើយសប្បាយមែនទែនន៍អ៊ុំ??

ខ៖ ចាសចាសនឹងហើយសប្បាយប។ បើសិនជានៅជួបជុំនឹងបងប្អូនគឺសប្បាយណាស់។

ក៖ ចាស។ អញ្ចឹងកាលដែលថាខ្មែរក្រហមចូលមកនឹង, តើអ៊ុំមានអាយុប៉ុន្មានឆ្នាំដែលអ៊ុំ???

ខ៖ អ៊ុំមានអាយុ ១៧ឆ្នាំ។

ក៖ អូ្ហ!! ក្រមុំហើយ។

ខ៖ ចាសនឹងហើយ! ក្រមុំតូមញ៉ឹមហាហា...

ក៖ ហាហា! គួរអោយស្រឡាញ់ចាស! ហើយអ៊ុំអត់ទាន់មានគ្រួសារទេ???

ខ៖ ចាសនឹងហើយ!

ក៖ នៅក្រោយទៀត??

ខ៖ ចាស!ដល់ពេលចូលមកហើយបាន, យួនចូលមក៧០ប៉ុន្មាន៧៤ ៧៥ នឹងឯង??? ៧០ជាង នឹងហើយ។

ក៖ ចាស៧៥។

ខ៖ ចាសនឹងហើយ, ៧៧ចប់។

ក៖ ៧៧ ចប់???

ខ៖ ចាសនឹងហើយ។

ក៖ អញ្ចឹងអ៊ុំបានរៀបការនៅឆ្នាំ ១៩៨៣???

ខ៖ ១៩៨៥។

ក៖ ១៩៨៥ ចាសចាស!

ខ៖ ប្រាំពិលប្រាំបីបានរៀបការ។ ហើយរៀបការនៅអាយុ ២៥។

ក៖ ចាសអ៊ុំ!

ខ៖ ចាសក្មេង...

ក៖ ចាសអ៊ុំ! អញ្ចឹងតើឪពុកម្ដាយរបស់អ៊ុំពួកគាត់បានស្លាប់អស់ហើយ???

ខ៖ ចាស! ស្លាប់អស់ហើយ នៅប៉ុលពតនឹងឯង។

ក៖ ប៉ុលពតសម្លាប់ពួកគាត់ទាំងអស់???

ខ៖ អត់ទេ អត់ទេ! ម្ដាយរបស់ខ្ញុំគាត់ខ្យល់។

ក៖ អ៊ូ!!!

ខ៖ គាត់អង្គុយៗ មើលកូនអោយគេគាត់ខ្យល់គរ។

ក៖ អ៊ូ!!!

ខ៖ ដួលអញ្ចឹងទៅក្រកៗអញ្ចឹងទៅស្លាប់ទៅ។

ក៖ ចាស! គេអោយគាត់មើលកូនហើអញ្ចឹងសម័យនឹងអ៊ុំ???

ខ៖ នឹងហើយគេអោយគាត់មើលកូនចៅអោយគេណាស់។

កៈ អ៊ូ!!! ចាស៕

ខៈ មើលចៅមើលកូនអោយគេណាស់, ចុះម៉ែគេធញវើការនោះ។

កៈ ចាស!

ខៈ អញ្ចឹងគាត់មើលកូនអោយគេ! កូនពីរ។

កៈ អ៊ូ!!!

ខៈ គាត់ស្លាប់អនោចអាធមណាស់គ្មានអ្នកណាទាន់ដង្ហើមគាត់ទេកាលណឹង។ គាត់តែឯងទេកាលណឹង។

កៈ ចាស! ចុះគេបំបែកអោយនៅផ្សេងគ្នាហ្វកាលនឹង។

ខៈ ចាសនឹងហើយ។

កៈ អញ្ចឹងកាលណឹងតើឪពុករបស់អ៊ុំតើគាត់បានធ្វើខាងផ្នែកអ្វីដែល???

ខៈ អត់ទេឪពុករបស់ខ្ញុំគាត់ធ្វើស្រែតើ។ ឪពុករបស់ខ្ញុំគាត់ខូចពេលដែលចូលមក, ឪបុករបស់ខ្ញុំខូចនៅឆ្នាំ ១៩៨៥។

កៈ ចាស!

ខៈ ហើយទៅបានគ្រួសាររបស់ខ្ញុំឃើញខ្ញុំនៅម្នាក់ឯង! បានអាណិតខ្ញុំហើយចូលដណ្តឹងខ្ញុំទៅ។

កៈ ចាសហាសហា!

ខៈ ហាហា!

កៈ ចាស! នឹងហើយ។ អញ្ចឹងកាលនៅក្នុងសម័យប៉ុលពតនឹងឪពុករបស់អ៊ុំ..?

ខៈ ឪពូកខ្ញុំគាត់នៅ។

កៈ ចាសនឹងហើយអ៊ុំ! តើប៉ុលពតបានប្រើគាត់អោយកាន់ខាងផ្នែងអ្វីដែលអ៊ុំ???

ខ៖ អូ!! គែអោយទៅខ្វាលគោ, នៅចម្ការខ្វាលគោ។

ក៖ ចាស! បីឆ្នាំ ប្រាំបីខែ???

ខ៖ ចាសនឹងហើយ!

ក៖ ចាស ហើយនឹង២៥ថ្ងៃនឹង, គឺមើលគោសុទ្ធតែម្តង???

ខ៖ ចានឹងហើយ! គឺមើលគោទៅ, ហើយគែអោយគាត់ទៅមើលចំការខ្លះទៅដាំដុះដំឡូងអីអញ្ចឹងទៅណាស់?៕

ក៖ ចាសអ៊ុំ!

ខ៖ ហើយដាំដុះទៅមើលគោហើយទៅយាមចម្ការអោយគេ។

ក៖ ចាសអ៊ុំ! អញ្ចឹងតើគ្រុមគ្រួសាររបស់អ៊ុំតើបានជួបគ្នាអីទេ?? ដូចថាពេលយប់ឡើងអីអញ្ចឹងហាស់???

ខ៖ ចាសអត់ទេ។ មិនដែលបានជួបម៉ែជួបអីទេ៕

ក៖ នៅក្នុងរយៈពេលបីឆ្នាំជាងនឹង???

ខ៖ ចាសនឹងហើយ!៕ មិនដែលបានជួបជាមួយម៉ែទេ គែអោយយើងចេញទៅចល័តឆ្ងាយចឹងហាស់។

ក៖ ចាសអ៊ុំ! សូមប្បីតែមុខអត់ដែឡបានឃើញគ្នាទាំងអស់ចឹងទៅអ៊ុំ???

ខ៖ ហ៊ឺ!!! ទៅបាត់មួយខែអញ្ចឹងទៅបានបានឃើញគ្នាម្តងអីអញ្ចឹងទៅ។

ក៖ អូ៎!!!

ខ៖ ពីប៉ុលពតនឹង។

ក៖ ចាស! ហើយអញ្ចឹងដោយសារតែអ៊ុំជាកូនពៅគែទៀត???

ខ៖ ចាសនឹងហើយ។

កះ អញ្ចឹងពេលនឹងតើអ៊ុំមានអារម្មណ៍បែបណាហើយតើវាពិបាកយ៉ាងម៉េចខ្លះដែល?? អ៊ុំអាចប្រាប់ខ្ញុំអោយអស់បានទេ???

ខះ អូ!!! ពិបាកណាស់ក្មួយអើយ!!! និយាយថាពិបាករកលេខដាក់គ្មានទេ។

កះ ចាសអ៊ុំ!

ខះ បញ្ហាគ្មានរឿងញាំនឹងតែម្តង។

កះ ចាសអ៊ុំ!

ខះ គ្មានអ្វីញាទេ! ចុះបបរមួយឆ្នាំងខ្លះគេដាក់បីបំប៉ុង។មួយខ្លះខ្មោតគេដាក់តែបីកំប៉ុងទេ។

កះ ចាសអ៊ុំ!

ខះ ហើយគែដួសចែកមួយការមួយការម្នាក់ទៅ។ ហើយជួនប៉ះថ្ងៃណាគែអត់មានបបរ, មានកន្តក់មួយដុំៗប៉ុននេះគេពូតអោយយើងញាំ។

កះ អត់មានបាយទេអ៊ុំ???

ខះ អត់មានបាយទេ។ អត់មានអោយយើងញាំទេញាំកន្តក់មួយពេលទៅ។ ហើយពេលល្ងាចឡើងបបរមួយចានទៅ។

កះ ចាសអ៊ុំ!

ខះ ហើយជួនណាខ្លះទៅក្រួចពោធិ៍សាត់ពីរអើអញ្ចឹងទៅហើយអត់បាយទៅ។

កះ ចាសអ៊ុំ!

ខះ អ៊ូយ!!! វេទនាណាស់កូនអើយ។

កះ ចាសអ៊ុំ!

ខះ និយាយពីថាវេទនារកលេខដាក់គ្មានទេ។ ហើយនិយាយបើនឹកឃើញថាបើសិនជាចូលមកមានតែបាយហើយនឹងអំបិលមិនដឹងថាជាឆ្ងាញ់ប៉ុនណាទេ។

កៈ ចាសអ៊ុំ!

ខៈ សព្វថ្ងៃនឹកឃើញពេលញាំ, នឹកឃើញតែអញ្ជឹង។

កៈ ចាសអ៊ុំ!

ខៈ នៅតែនឹកឃើញសម័យប៉ុលពតគែធ្វើបាបយើងអញ្ជឹង។

កៈ ចាសអ៊ុំ!

ខៈ មកសព្វថ្ងៃយើងបានមកដល់ប៉ុននេះយើងសប្បាយហើយវាសប្បាយណាស់។ អ៊ុំលំបាកណាស់។ ហើយយប់ឡើងចង់មកគេងចង់មកនៅជាមួយម៉ែ! អ៊ុំលួចតែមកហើយគេចាប់បានគេស្ដីអោយគេជេរយើងដូចស្អីអញ្ជឹង។

កៈ ចាសអ៊ុំ!

ខៈ ឈប់រៀងមិនហ៊ានធ្វើទៀតទេខ្លាចខុសច្បាប់។

កៈ ចាសនឹងហើយអ៊ុំ។

ខៈ ខ្លាចគេណាស់! ហើយគែថាអោយអ្នកមាន។ កូនគេដាលអោយពូជយើងស្អីៗសព្វគ្រប់ហើយ។

កៈ ចាសនឹងហើយអ៊ុំ! យើងមានគែដាលយើងទៀតកាលណឹងន៍អ៊ុំ៕

ខៈ ចាសនឹងហើយ នឹងហើយ! យើងចូលទៅ, ហើយអ្នកដាលសុទ្ធតែជាអ្នកក្រទេដែលដាលយើងហ្វ។

កៈ ហាហា! អញ្ជឹងអ្នកក្រច្រណែនអ្នកមានន៍អ៊ុំ???

ខៈ ចាសនឹងហើយអ្នកក្រច្រណែនអ្នកមាន! នឹងហើយ, គែឃើញយើងមាននឹងហើយ។

កៈ ចាស! អ៊ូយ!! នឹងហើយ។ អញ្ជឹងបានថាកាច្រណែននឹងមានតាំងពីដើមមកម្ល៉េះណ៎អ៊ុំ???

ខៈ ចាសនឹងហើយ! មានតាំងពីដើមមកម្ល៉េះ។ មានតាំងពីដើមមកមែននឹងឯងការច្រណែន។

កៈ ចាសអ៊ុំ! នឹងបានថា។ អញ្ចឹងតើអ៊ុំមានដូចថាៈ ការលំបាកអ្វីផ្សេងពីនឹងទៀតដែលឬអត់ទេ អ៊ុំ???

ខៈ  លំបាកតែពីប៉ុលពតនឹងឯង។

កៈ អញ្ចឹងលំបាកតែពីប៉ុលពតទែន៍អ៊ុំ??

ខៈ នឹងហើយ! កាលពីពែលដែលចូលមកអ៊ុំអត់មានកំបាកទេ។

កៈ ចាសអ៊ុំ!

ខៈ ចូលកមលអ៊ុំនៅជាមួយនឹងបងៗ ហើយបងបងគាត់ចេញទៅដើររកស៊ីនៅភ្នំពេញនឹង។ បងស្រីអ៊ុំពីរនាក់ហាស់???

កៈ ចាសអ៊ុំ!

ខៈ បងស្រីគាត់ទៅរកស៊ីទទៅ, គាត់មានអោយញាំសន្ទឹកន្ទាប់មកទៅមានបាយមានអង្គរពេញការ៉ុង។

កៈ ចាសអ៊ុំ!

ខៈ ហើយលុយចាយពេញដៃមើលកូនអោយគាត់ទៅ។ ហើយអ៊ុំនៅផ្ទះមើលក្មួយទៅ។

កៈ ចាសអ៊ុំ!

ខៈ អត់មានពិបាកអីទេ។ ហើយដល់ពេលដែលចាប់ដៃមានគ្រួសារគឺសប្បាយរហូត។

កៈ ចាសចាស!

ខៈ គឺសប្បាយរហូត អត់ដឹងថាអត់អីទេ, ដឹងតែមាន។

កៈ ចាសអ៊ុំ!។

ខៈ ហាហា....

កៈ ចូលដូចថាយើងធ្លាប់មានហើយ! ដល់ពេលចូលដល់រួចពីប៉ុលពតនឹងហើយយើងមានម្តងទៀត។

ខៈ អើ! នឹងហើយយើងមានម្តងទៀត។ មាននៅពីក្រមុំយើងមាននៅជាមួយនឹងបងៗហាស់?? ។

កៈ ចាស!

ខៈ គាត់មិនដែលអោយប្អូនអត់ទេ។ គាត់នៅអោយលុយយើងចិញ្ចឹមយើងចុះពួកគាត់ដើររកស៊ីហូ??

កៈ ចាសអ៊ុំ!

ខៈ នៅមើលក្មួយៗអីអញ្ចឹងទៅ, ហើយនៅមើលក្រវ៉ាន់អីនឹងឯង។

កៈ ចាសអ៊ុំ!៕

ខៈ ទាំងអស់គ្នាអញ្ចឹងទៅ។

កៈ ចាស!

ខៈ ហើយដល់ពេលខ្ញុំមានគ្រួសារខ្ញុំបែកទៅក៏ដឹងតែមានរហូតទៅ ហើយមានកូនមានចៅរហូតមកដល់សព្វថ្ងៃនេះទៅ។

កៈ ចាសល្អមែនទែនអ៊ុំ។

ខៈ ចាស! សប្បាយសប្បាយ។

កៈ ចាស! អញ្ចឹងកាលដែលអ៊ុំនៅសម័យប៉ុលពតនឹងវាពិបាកមែន, មែនដែលឬទេអ៊ុំ???

ខៈ អូ្វពិបាកណាស់!!!

កៈ ចាសអ៊ុំ! អញ្ចឹងកាលពីពេលដែលអ៊ុំនៅជួបជុំជាមួយនឹងគ្រុកគ្រួសារហាស់តើអ្វីទៅដែលធ្វើអោយអ៊ុំាប្បាយចិត្តជាងគេ?? ដូចថាបានរស់នៅជាំមួយនឹងគ្រុមគ្រួសារប្រាកដជាំយើងសប្បាយចិត្តហើយន៍អ៊ុំ???

ខ៖ ចាសនឹងហើយ!

ក៖ ហើយបងប្អូនរបស់អ៊ុំច្រើនទៀតនោះ។

ខ៖ ចាសនឹងហើយ។

ក៖ហើយឈ្មោះគ្នាអីវៃគ្នាអីតិចតូចមែនប៉ុន្តែនៅតែសប្បាយមែនដែលឬទេអ៊ុំ???

ខ៖ ចាសនៅតែសប្បាយ។

ក៖ អញ្ចឹងតើអ៊ុំចាំគ្រាអ្វីជាងគេនៅពេលដែលអ៊ុំបានរស់នៅជាមួយបងប្អូនតបស់អ៊ុំហើយនឹងឪពុកម្ដាយរបស់អ៊ុំហាស់???

ខ៖ អូ្វ!! ចងចាំពេលដែលនៅពី...ដូចពីកាលដែលរស់នៅជាមួយម៉ែ៖ ចងចាំថាបងៗគឺថាអាណិតបងៗគឺស្រឡាញ់ប្អូនៗណាស់។

ក៖ ចាសអ៊ុំ!

ខ៖ ដូចកាលដែលនៅពីប៉ុលពតអញ្ចឹងបើថាដូចត្រូវគេចែកបបរអញ្ចឹងគាត់ទុកអោយប្អូនហើយគាត់សុខចិត្តអត់ បងៗ សុខចិត្តអត់ទុកអោយប្អូន អោយប្អូនពៅខ្ញុំវាតូចជាងគេ។

ក៖ ចាសអ៊ុំ។

ខ៖ អាណិតបងៗបានបបរមកទុកអោយប្អូន។ ហើយម៉ែខ្ញុំក៏អញ្ចឹងដែលបានបបរមកទុកអោយកូន៕

ក៖ ចាសអ៊ុំ!

ខ៖ ហើយគាត់អត់ហ៊ានពិសាទេខ្លួនគាត់ គាត់សុខចិត្តប៉ះស្លឹកបាស់ចេះតែដាក់ជាមួយនឹងទឹកអីហើយចេះតែហុតៗទៅ។

ក៖ ចាសអ៊ុំ!

ខ៖ ហើយទទេទៅគ្មានកាកគ្មានអីទេ! ហើយមានបាយមានបបរកាកទុកអោយកូនមក។

ក៖ ចាសអ៊ុំ!

ខ៖ អញ្ចឹងហាស់! ហើយមានការកំសត់ច្រើន។

ក៖ ចាសអ៊ុំ!

ខ៖ ពុកម៉ែហើយនឹងបងប្អូនទាំងអស់នឹង។ លំបាកណាស់ហើយលំបាកតែពីពេលប៉ុលពតនឹងឯង។

ក៖ ចាសអ៊ុំ! នឹងហើយកុំអីគ្រុមគ្រួសាររបស់អ៊ុំត្រូបស្រួយតាំងពីនឹងមក។

ខ៖ អ្វូនឹងហើយកុំអីត្រូវស្រួយ..!!

ក៖ ហើយបើសិនជាទព្យសម្បត្តិតាំងពីនឹងមកហើយនៅសល់ដល់នវទៀតហាស់...?

ខ៖ អ្វូយ!!!

ក៖ មិនដឹងថាមានយ៉ាងណាទេណ៌អ៊ុំ???

ខ៖ ចាសនឹងហើយ។

ក៖ ចាសហើយបើសិនជាគិតទៅវារៀងស្ដាយដែល។

ខ៖ ចាសវារៀងស្ដាយដែលនឹងហើយមិនដឹងធ្វើម៉េច។

ក៖ ប៉ុន្តែឥឡូវនេះអ៊ុំមានវិញហើយ! អ៊ុំលេងសូវស្ដាយហើយណ៌អ៊ុំ???

ខ៖ ហាហា! ឥឡូវមានវិញពិតមែនតែព្រាត់ម៉ែព្រាត់ឪពុកហើយបងៗអស់រលីង។

ក៖ ចាសចាអ៊ុំ!

ខ៖ នៅតែពីរនាក់បងប្អូន។

ក៖ ចាសអ៊ុំ! បើនិយាយទៅអាណិតពួកគាត់ដែល ដោយសារតែពួកគាត់បានស្លាប់ទៅហើយអត់បានមកស្គាល់ជីវិតដូចជាយើងនៅសម័យនេះ ថាវារីកចម្រើនអីម៉េចខ្លះ។

ខ៖ អើនឹង អើអញ្ចឹងឯង។

ក៖ ចាសអ៊ុំ! អញ្ចឹងអ៊ុំអរ..! តើអ៊ុំមានចាំឈ្មោះជីដូនជីតារបស់អ៊ុំដែលឬទេ???

ខ៖ ចាស ចាំ!

ក៖ ចាសអញ្ចឹងសូមប្រាប់បានទេអ៊ុំ???

ខ៖ ឪពុកខាងណា???

ក៖ខាងម្ដាយរបស់អ៊ុំសិនមក។

ខ៖ ខាងម្ដាយ៖ ជីដូនរបស់ខ្ញុំឈ្មោះ យាយអ៊ុច។

ក៖ ចាស!

ខ៖ ហើយតា តា ចាន់។

ក៖ ចាសអ៊ុំ! គាត់ឈ្មោះដូចជាតារបស់ខ្ញុំដែល។

ខ៖ ចាសនឹងហើយ។ តា ចាន់យាយ អ៊ុច។

ក៖ ចាសអ៊ុំ!

ខ៖ ហើយបើសិនជាខាងឪពុកខ្ញុំឯនោះ៖ តាជុំ យាយ ឡុង។

ក៖ ចាសអ៊ុំ!

ខ៖ នឹងហើយ! នឹងហើយឈ្មោះជីដូន។

ក៖ ចាស! អញ្ចឹងតើអ៊ុំមានចាំជីដូនជីតាខាងប្ដីរបស់អ៊ុំដែលឬទេ?? តើគាត់មានបានប្រាប់អ៊ុំដែលឬទេ???

ខ៖ មាន មាន!

ក៖ ចាសអ៊ុំ!

ខ៖ ឈ្មោះតាឡោ, ហើយយាយដូច ជាស្អីទេ...

ក៖ ចាសអ៊ុំ!

ខ៖ តែបើម្ដាយខ្ញុំស្គាល់។

ក៖ ចាសអ៊ុំ! អញ្ចឹងម្ដាយឈ្មោះអ្វី???

ខ៖ ម្ដាយឈ្មោះ អ៊ូម ឪពុកឈ្មោះ នឿម! ឡោនឿម ម្ដាយឈ្មោះ ចាន់នឿម។

ក៖ ចាសអ៊ុំ!

ខ៖ ចាសនឹងហើយ!

ក៖ ចាសអ៊ុំ! អញ្ចឹងតើមិញនឹងអ៊ុំបានប្រាប់ខ្ញុំហើយតើហ៊ីពីឈ្មោះឪពុកម្ដាយរបស់អ៊ុំហាស់???

ខ៖ ចាសនឹងហើយបានប្រាប់ហើយ។

ក៖ ចាស! អញ្ចឹងតើអ៊ុំមានចាំពីថ្ងៃខែហើយឆ្នាំកំណើតរបស់ពួកគាត់ដែលឬទេអ៊ុំ???

ខ៖ អ៊ូដឹងតែ ឆ្នាំប៉ុន្តែមិនដឹងថាឆ្នាំកំណើតខែអី។

ក៖ ចាស! ឆ្នាំនឹង។

ខ៖ ឪពុករបស់ខ្ញុំឆ្នាំ ថ្មាស់។

ក៖ អ៊ូ!!!

ខ៖ ហើយបើសិនជាគាត់នៅមួយរយហើយ។

ក៖ អ៊ូ!! មួយរយឆ្នាំហ៊ីអ៊ុំ???

ខ៖ ចាសនឹងហើយមួយរយឆ្នាំ។

ក៖ ចាស អ៊ូយ...

ខ៖ ហើយបើម្ដាយរបស់ខ្ញុំគាត់មានអាយុដំណាលនឹងសម្ដេច។

ក៖ អ៊ូសម្ដេចតាយើងនឹងហ៊ីអ៊ុំ???

ខ៖ ចាសនឹងហើយ! សម្ដេចតាយើងនឹង។

កៈ ចាសអ៊ុំ!

ខៈ ហើយម្ដាយខ្ញុំគាត់ឆ្នាំ ចរ។

កៈ ចាស! ៩០ឆ្នាំជាងដែលន៏អ៊ុំ???

ខៈ ចាសនឹងហើយ! នឹងហើយ៕

កៈ អ៊្វយពួកគាត់មានអាយុច្រើនណាស់។

ខៈ ចាសនឹងហើយនឹងហើយ។

កៈ ចាស! អញ្ចឹងតើអ៊ុំមានចាំពីទីកន្លែងកំណើតរបស់ពួកគាត់ដែឡឬទេហើយពីជីដូនជីតារបស់ពួកអ៊ុមដែល???

ខៈ ជីដូនជីតាស្រុកកំណើតរបស់ពួកគាត់នៅទីនេះឯង។

កៈ អ៊ូចាស!

ខៈ ហើយឪពុករបស់ខ្ញុំជីជីនជីតារបស់គាត់នៅនឹងវត្តតាមិម។

កៈ អ៊ូ!! អូខុសភូមិ។

ខៈ ចាសនឹងហើយខុសភូមិ។

កៈ ចាសអញ្ចឹងតើអ៊ុំមានចាំពី...តើគាត់មានបានប្រាប់ប្រវត្តិសេហ្នោរបស់ពួកគាត់ដល់អ៊ុំដែលឬទេអ៊ុំពួកគាត់បានជួបគ្នាយ៉ាងម៉េចហើយធ្វើម៉េចបានបានគ្នាអញ្ចឹងហាស់អ៊ុំ??? អញ្ចឹងហាស់!!

ខៈ អ៊ូ!! គាត់ថាគែមកលេងផ្ទះហើយគេឃើញ។ គេឃើញម៉ែ។

កៈ អ៊ូ!!!

ខៈ គែមកលេង, គេមកកាប់ឆ្ការព្រៃចម្ការគេនៅជិតនឹងក៏ឃើញ! ហើយក៏គែប្រាប់ឪពុកម៉ែគេមកចូលស្ដីដណ្ដឹងការទៅ។ ហើយក៏រៀបការទៅ។

កៈ អ៊ូ!!! ចាសស្រួយៗហាស់ន៍អ៊ុំ?? ហាហា...

ខ៖ ចាស! ស្រួយៗហាហា....៕ នឹងហើយ!

ក៖ ហាហា! អញ្ចឹងតើអ៊ុំមានចាំអ្វីផ្សេងទៀតដែលឬអត់ពីពួកគាត់ឬក៏មានតែប៉ុនណឹង???

ខ៖ អ៊្វពួកគាត់! គឺពួកគាត់ចាប់ដៃគ្នាឡើងគឺដឹងតែធ្វើការអញ្ចឹង, ធ្វើស្រែធ្វើចម្ការនឹង...!

ក៖ ចាសអ៊ុំ!

ខ៖ ប៉ុន្តែធ្វលស្រែធ្វើចម្ការរបស់ពួកគាត់ពីបានផលហាស់???

ក៖ ចាសអ៊ុំ!

ខ៖ ពីដើម! ផលច្រើនណាស់ មួយឆ្នាំ មួយឆ្នាំគាត់ម៉ៅច្រើនណាស់ក្រូចហើយនឹងម្ពាក់របស់គាត់។

ក៖ ចាសអ៊ុំ!

ខ៖ ទិញស្រែទិញចម្ការបានឡើងធ្វើចែកកូនគ្រប់គ្នា។

ក៖ ចាសអ៊ុំ!

ខ៖ ខំណាស់! ហើយនៅតែនឹងចម្ការនឹងឯង។ ហើយសក់ក្បាលឡើងកាមើងៗឪពុក។

ក៖ ចាសអ៊ុំ !

ខ៖ ហើយម៉ែគាត់នៅផ្ទះមើលតែកូនទេកូនឡើងដប់។

ក៖ កូនឡើងដប់???

ខ៖ ចាសនឹងហើយ។

ក៖ អ៊្វយ!! ចុះអ៊ុំឥឡូវនេះអ៊ុំមានកូនប៉ុន្មានហើយ?? ខ្ញុំភ្លេចសួរអ៊ុំ។

ខ៖ ខ្ញុំមានកូនបី។

ក៖ អ៊ុំមានកូនតែបីទេចាស!

ខ៖ ចាសតែបី។

ក៖ ចាស! តើអ៊ុំមានការពិបាកក្នុងការចិញ្ចឹមពួកគាត់ដែលឬទេ???

ខ៖ អ៊ូ! អត់ពិបាកទេ។

ក៖ អ៊ូ! អត់ពិបាកទេន៏អ៊ុំ៕

ខ៖ ចាសស្រួយណាស់។

ក៖ ចាសអញ្ចឹងអ៊ុំបានសុទ្ធតែកូនស្រួយហើយល្អ។

ខ៖ ចាសនឹងហើយ។ អត់មានលំបាកលំបិនអីទេគឺនិយាយពីថាស្រួយ ហើយគឺសប្បាយចិត្តតែម្តង។

ក៖ អ៊ូ!!! ខ្ញុំសប្បាយចិត្តបានឮអញ្ចឹងហាស់អ៊ុំ។

ខ៖ ចាសនឹងហើយ។

ក៖ ចាសហើយឪពុកម្តាយខ្លះពួកគាត់ក្នុងការចិញ្ចឹមបីបាច់កូនអីចឹងហាស់។

ខ៖ ចាសនេះអត់ទេ។

ក៖ ខ្លះកូនកើតមកយំរករឿងរកអីអញ្ចឹងហាស់អ៊ុំ៕

ខ៖ ចាស!

ក៖ តែកូនអ៊ុំពួកគាត់អត់ទេ??

ខ៖ ចាសពួកគាត់អត់ទេ។

ក៖ ចាស! អញ្ចឹងខ្ញុំក៏គិតដែលថាម្តាយរបស់អ៊ុំគាត់មានកូនច្រើមពិតមែនតែប្រហែលជាំគាត់ស្វូវលំបាកទេដោយសារកូនស្រួយដែល។

ខ៖ ចាស! អត់ពិបាកដែលកូនច្រើនប៉ុន្តែស្រួយៗនឹងហើយ។ ចាស

ក៖ ចាស!

ខ៖ ស្តាប់ដំបូន្មានឪពុកម្តាយហើយខ្លាចតែម្តង។

ក៖ ចាសអ៊ុំ!

ខ៖ អត់មានលំបាកអ្វីទេ។

ក៖ អូ្ហ!! ពរជ័យណាស់អ៊ុំ នឹងពរជ័យហាអ៊ុំ៕ ហាហា..

ខ៖ ហាហា ពរជ័យ។ ហាហា

ក៖ ចាស! អញ្ចឹងដូចជាថាអ៊ុំមានចាំអ្វីពីឪពុកម្តាយរបស់អ៊ុំដែលឬអត់??? ដូចថាពីមុនដែលគាត់ស្លាប់ទៅហាស់? តើគាត់បានផ្តែផ្តាំអ្វីដល់អ៊ុំដែលឬអត់??? ឬក៏តើអ៊ុំបានចងចាំអ្វីខ្លះពីពួកគាត់???

ខ៖ អូ្ហ!! គាត់គិតដែឡតើ! កាលដែឡពីប៉ុលពតអញ្ចឹង។ គាត់ថា៖ កូនអើយ កូនឯងនៅតូចជាងគែម៉ែអាណិត! មិនបានទាន់បានដឹងអី។ គេមានប្តីមានប្រពន្ធ។ ចំណែកកូនឯងវិញវានៅតូចម៉ែអាណិត។ ពេលដែលគាត់ចេញទៅណាគាត់អោបហាស់??។

ក៖ ចាសអ៊ុំ!

ខ៖ រហូតដល់ឪពុករបស់ខ្ញុំគាត់ចូលមក គាត់ទឹមតែស្លាប់ដែលចូលមក ដែលរៀតណាមចូលមកហាស់!?

ក៖ ចាស!

ខ៖ គាត់ថាបើឪពុកខូចទៅ! កូននៅម្នាក់ឯងមិនដឹងថាកូនលំបាកលំបិនប៉ុនណា?៕

ក៖ ចាសអ៊ុំ!

ខ៖ ចាស! ហើយទៅខ្ញុំវាមិនលំបាកវាទៅជាស្រួយ..!!

ក៖ ចាសអ៊ុំ!

ខ៖ នឹងគាត់គិតហាស???

ក៖ ចាសអ៊ុំ!

ខ៖ ហើយមុននឹងគាត់ខូចគាត់ថាកុំអោយកូនអាញ់ពិបាកនឹងរឿងផ្ទះហើយគាត់បានធ្វើផ្ទះនេះអោយមួយ។

ក៖ ចាសអ៊ុំ!

ខ៖ ប្រុងប្រៀបអោយកូនរួចស្រេចហើយបានគាត់ស្លាប់ទៅ។

ក៖ ចាសអ៊ុំ!

ខ៖ ចាស!

ក៖ ផ្ទះដែលអ៊ុំរស់នៅសព្វថ្ងៃនេះមែន???

ខ៖ ចាស! នៅខាងលើនឹងហាស់?។

ក៖ ខាងលើ។

ខ៖ ហើយដល់ពេលអ៊ុំមានគ្រួសារទៅបាន បានរៀបអីអញ្ចឹងទៅ។

ក៖ បានរៀបខាងក្រោម??

ខ៖ ចាសនឹងហើយ។

ក៖ ចាស! អូ!!! នេះតាំងពីអើយមកហូអ៊ុំ???

ខ៖ ចាសនឹងហើយ! បើគិតទៅគឺតាំងតែពី៨០គត់មក។

ក៖ ហើយបើគិតយូរឆ្នាំដែលហើយ។

ខ៖ ចាសនឹងហើយ។

ក៖ ប៉ុន្តែផ្ទះមើលទៅនៅតែស្អាតហើយថ្មីទៀត។

ខ៖ ហ៊ឹម..ហាហា៕

ក៖ ដោយសារតែអ៊ុំសំអាតហើយមើលថែរក្សាបានល្អហើយមើលទៅ។

ខ៖ ហាហា! កូនចៅចេះតែធ្វើនៅទៅ។

ក៖ ចាសអ៊ុំ! ហើយឃើញប៉ុននេះអាចនៅបានយូរឆ្នាំទៀតណាអ៊ុំ៕

ខ៖ ចាសនឹងហើយ។

ក៖ ហាហា..!

ខ៖ ហាហាហា..!

ក៖ ចាំមើលអាចដល់ចៅរបស់អ៊ុំទៀត។

ខ៖ ចៅមានហើយ។

ក៖ ចាស! អញ្ចឹងតើអ៊ុំមានចាំអ្វីផ្សេងដែលទៀតទេអ៊ុំ???

ខ៖ គ្មានអីទេ កាលណឹងវាគ្មានលំបាកលំបិននអីអោយគិតអីគឺអត់មាន។

ក៖ ចាសអ៊ុំ! បើនិយាយទៅជីវិតរបស់អ៊ុំពិបាកតែនីជំនាន់ប៉ុលពតនឹងឯង??

ខ៖ ចាសនឹងហើយ! ពិបាកតែនៅជំនាន់ប៉ុលពតនឹងឯង។

ក៖ ចាស! អញ្ចឹងតើអ៊ុំមានបងប្អូនណាដែលពួកគាត់រស់នៅក្រៅប្រទេសដែលឬទេ???

ខ៖ អត់មានទេ។

ក៖ អត់មានទេន៎អ៊ុំ។

ខ៖ អត់មានទេ! គឺនៅស្រុកខ្មែរទាំងអស់។

ក៖ នៅស្រុកខ្មែរទាំងអស់ណ៎អ៊ុំ! អូ!!! ចាសនឹងហើយដោយសារខ្ញុំភ្លេច។ ដោយសារតែប្រាំពិល នាក់នឹងគាត់បានចែកឋានទៅអស់ហើយ។

ខ៖ ចាសនឹងហើយ។

ក៖ ចាសនៅអ៊ុំពីរនាក់។

ខ៖ ចាសនៅពីរនាក់។

ក៖ ហើយនឹងបងរបស់អ៊ុំ!

ខ៖ ចាសនឹងហើយ!

ក៖ ចាស! អញ្ចឹងតើអ៊ុំដែលបានធ្លាប់ទៅលេងប្រទេសគេទេ??

ខ៖ អត់!!

ក៖ ដូចជាប្រទេសថៃអីអញ្ចឹងហាស់???

ខ៖ អ៊ូ!! អត់ទេ។ អត់ដែឡបានទៅដើរលេងនៅឯណាទេ។ បានតែដើរលេងនៅតែក្នុងស្រុកយើងនេះឯង។

ក៖ ចាសអ៊ុំ!

ខ៖ ហាហា....!

ក៖ ហើយតើបានដើរបានច្រើនខេត្តច្រើនអីលែហើយនៅអ៊ុំ???

ខ៖ ដើរ, ដើរបានច្រើនខេត្ត។

ក៖ ចាស! ហើយអ្នកខ្លះគាត់សូម្បីតែផ្សាររោងល្ខោនគាត់អត់ទាន់បានទៅស្គាល់ផង៕ ហាហា

ខ៖ ហាហាហា..!

ក៖ អ៊ុំដើរ! គ្រាន់តែឥឡូវអ៊ុំមិនទាន់បានទៅថៃទៅអីព្រោះអីប្លាស្ព័រ, ប្លាស្ព័រអីមានអស់គ្រាន់តែមិនទាន់បានចេញដើរនៅ៕

ក៖ ចាសអ៊ុំ!

ខ៖ វាកំពុលតែរវល់នឹងហា, ដោយសារតែកូនសុទតែជាអ្នកធ្វើការងារទាំងអស់អញ្ចឹង។

ក៖ ចាសអ៊ុំ! អញ្ចឹងបើសិនជាអ៊ុំចង់ដើរក្រៅពីប្រទេសក្រៅពីខេត្តប្រទេសរបស់យើងហាស់??

ខ៖ ចាស!

កៈ តើអ៊ុំចង់ទៅប្រទេដមួយណាដែល???

ខៈ ចង់ទៅលេងប្រទេសថៃ។

កៈ អូ្វ!!! អ៊មចង់ទៅលេងថៃ៕ អញ្ចឹងតើអ៊ុំចង់ទៅលេងអាមេរិចអីដែលឬទេ???

ខៈ អូ្វចង់!! ប៉ុន្តែយើងគ្មានសម្ថតិភាពទៅទេ។ហាហា

កៈ ហាហា! មើលអត់ឃើញដែលអ៊ុំ។

ខៈ ចាស! គ្មានសម្ថត្តិភាពទេ។

កៈ ចាស! ហាហា។ ចងង់ទៅលេងថៃហ្វអ៊ុំ??

ខៈ នឹងហើយ!៕

កៈ ចាស! មូហេតុអ្វីដែលធ្វើអោយអ៊មចង់ទៅលេងនៅថៃនឹង???

ខៈ ទេឃើញគេទៅហើយគេថាសប្បាយ ហើយកូនវាធ្លាប់ទៅ។

កៈ អូ្វ!!!

ខៈ កូនថាម៉ែអើយ! ថៃសប្បាយណាស់ជិះកបាល់ហោះជិះអី៕ អើចាំមើលថ្ងៃណាម៉ែទៅម្តងចាំមើលកូនទំនេរទៅមានប្លាស្ត័រប្លាស់ទាំងអស់តែគ្មានឹង៕

កៈ ចាស! ហើយចុះកាលពេលកូនទៅអត់យកម៉ាក់ទៅផង។

ខៈ ហាហា!

កៈ ហាហា! នឹងហើយអ៊ុំ។ អញ្ចឹងតើអ៊ុំអាចរៀបរាប់ពីខ្សែជីវិតរបស់អ៊ុំពីក្មេងរហូតដល់អ៊ុំធំឡើងហាស់។ តើអ៊ុំបានធុះឡើងយ៉ាងម៉េចដែល? ដោយសារតែខ្ញុំដឹងថាពេលអ៊ុំធំឡើង, និយាយគឺពេលដែលអ៊ុំកើតមក គឺជីវភាពរបស់អ៊ុំគឺធូរធា។

ខៈ ចាសនឹងហើយ!

កៈ អញ្ចឹងតើអ៊ុំអាចប្រាប់ដំណើរពីខ្សែជីវិតរបស់អ៊ុំមករហូតបានមកដល់ប៉ុននេះ???

ខ៖ អ្ហូ!!ខ្សែជីវិតនឹងគឺវាល្មមធម្មតា! បើសិនជាំអោយលំបាកមិនលំបាកទេ។ គឺល្មមធម្មតាអាចដូចតែគេដូចតែឯងបានដែល។ និយាយទៅគឺមធ្យម។

ក៖ ចាសអ៊ុំ!។

ខ៖ នឹងហើយ! វាមិនលំបាកអីយ៉ាងណា, វាមិនអីទេ។ មករហូតជីវិតនេះហូ។ ខ្លាចខ្សែជីវិតទៅមុខទៀតមើលវាមិនឃើញ៕

ក៖ ចាស!

ខ៖ សព្វថ្ងៃនេះវាបារម្ភនឹងឈឺ។ សព្វថ្ងៃនេះវាមានរោគ។

ក៖ អ្ហូ!! តើអ៊ុំឈឺអ្វីដែល មានជីង្ហឺអ្វីដែល???

ខ៖ ជីង្ហឺលើសឈាម។

ក៖ អ្ហូចាស!

ខ៖ សព្វថ្ងៃនេះថ្នាំលេបរាល់ថ្ងៃនឹង។

ក៖ ចាស!!

ខ៖ នឹងហើយ! សព្វថ្ងៃនេះខ្សែជីវិតគឺលំបាកតែប៉ុននឹងឯង។ រឿងឈឺយើងមើលវាមិនឃើញចុះបើរោគយើងនឹងវាខ្យល់ លើសឈាមងាប់ដៃងាប់ជើងទៅវាលំបាកកូនចៅហាស់???

ក៖ ចាសនឹងហើយអ៊ុំ។

ខ៖ នឹងហើយ។ កូនចៅគ្នាធ្វើការគ្នាអីទៅគ្នាលំបាក។

ក៖ ចាសអ៊ុំ!

ខ៖ ហើយសព្វថ្ងៃគ្មាននឹកឃើញអ្វីទេនឹកឃើញតែប៉ុននឹងឯងសព្វថ្ងៃហ្ហូ!!!

ក៖ ចាស! អញ្ចឹងអ៊ុំត្រូវតែខំថែរក្សាសុខភាពរបស់ជុំអោយបានល្អ។

ខ៖ ចាសនឹងហើយ!

កះ ចាស! ដើម្បីបានទៅលេងហើយបានមើលថៅរីកពាយអោយបានយូរហាស់អ៊ុំ៕

ខះ ចាសនឹងហើយ នឹងហើយ។

កះ ចាស!

ខះ អញ្ជឹង។

កះ ចាស! ហើអ្វ!! ដូចជាខ្ញុំអត់ទាន់សួរអ៊ុំ។ កាលដែលអ៊ុំកើតទាន់សម័៧យប៉ុលពតនឹងតើអ៊ុំមានអាយុប៉ុន្មនាឆ្នាំដែល??? ១៧ហើអ៊ុំ៕??

ខះ ចាស ១៧។

កះ ចាស! ហើយតើកាលនឹងគែបានប្រើអោយអ៊ុំធ្វើអ្វីដែល???

ខះ អ្វពីមុននឹងគែអោយនៅកុមារ។

កះ ចាស!

ខះហើយបានប៉ុន្មានឆ្នាំនឹងគែអោយចូលនារី ចូលនារីគេអោយទៅ, ក៏គេមិនអោយនឿយហាត់ដែល។

កះ ចាស!

ខះ ទៅគេប្រើអោយប៉ះតែត្រគូន។ នៅក្បែរចុងភៅអីតាក់តិចទេកាលណឹង។ តិចៗនឹងចេះតែជួយគែទៅ។

កះ ចាស!

ខះ នឹងហើយចឹងឯង។ វាមិនពិបាកប៉ុន្មានទេ។ វាបិបាកតែរឿងអត់អីញាំតែប៉ុនណឹងឯង។

កះ ចាស! បើនិយាយទៅខ្សែជីវិតរបស់អ៊ុំទោះបីជានៅជំនាន់សម័យប៉ុលពតក៏មិនពិបាកអីខ្លាំង។

ខះ ហាហា...!!

កៈ ចាស! ហើយអ៊ុំពិតជាសំណាងណាស់អ៊ុំ!។

ខៈ ចាសសំណាង, ទាស់តែញ៉ាំអីអត់គ្រប់គ្រាន់តែប៉ុននឹងឯង។

កៈ គ្រាន់តែអត់បានញ៉ាំអីគ្រប់គ្រាន់។

ខៈ ហើយបើអោយលំបាកក៏អត់មានអីលំបាកច្រើនទេ។

កៈ ចាស!! ហើយនេះបើសិនជាប៉ុលពតអោយអ៊ុំញ៉ាំគ្រប់គ្រាន់គឺអ៊ុំស្រួយប៉ុនដោយ។

ខៈ ចាស! នឹងហើយស្រួយប៉ុនដោយ។

កៈ ហាហា..!

ខៈ ហាហា...!

កៈ មែននឹងគេអោយអ៊ុំប៉ះតែត្រគួន???

ខៈ ចាសនឹងហើយ! គែអោយប៉ះត្រគួនហើយនឹងបោះបន្លែ។

កៈ ចាស! ជីវិតរបស់អ៊ុំបើនិយាយទៅឡូយយ៉ាងដែល។ គេថាសំណាងហាស់អ៊ុំ៕

ខៈ ហាហា...!

កៈ ប្រហែងជាអ៊ុំធ្វើបុណ្យដល់ហើយមើលទៅ។

ខៈ ចាសនឹងហើយ!

កៈ ដោយសារតែខ្ញុំសម្ភាសកន្លងមកពួកគាត់វេទនាហើយពួកគាត់ឈ្លានខ្លាំងហើយពួកគាត់បានធ្វើការហួសពីកម្លាំងចឹងទៅណាស់៕

ខៈ ចាស!

កៈ ចាស! ប៉ុន្តែការងាររបស់អ៊ុំគឺថាស្រាលដែល។ គឺប៉ះតែត្រគួនហើយនឹងបន្លែ??

ខៈ ចាស! ប៉ះតែត្រគួនហើយនឹងបន្លែ។

ក៖ ចាស! អញ្ចឹងនៅក្នុងរយៈពេលបីឆ្នាំនឹងអ៊ុំធ្វើតែប៉ុននឹងគត់?? អ៊ុំអត់មានគេដូរមុខដំណែងការងារអោយធ្វើអ្វីផ្សេងទៀតទេអ៊ុំ???

ខ៖ មានដែល! ពេលខ្លះគែអោយទៅដក ទៅស្ទូងគេអោយយើងទៅដកសំណាបអីដែល។

ក៖ ចាស!

ខ៖ តែដល់ពែលគេឃើញយើងវាតូចអញ្ចឹងទៅ, គេមិនសូវអោយយើងធ្វូលអីទេ។ ធម្មតាចឹងហាស់៕

ក៖ អូ្វ!! វាយ, ឃើញទេនេះជាសំណាងរបស់អ៊ុំហាស់!! ឃើញទេអ៊ុំ??? ហ៊ឹម....!

ខ៖ ហាហាចាស។

ក៖ ចាស!

ខ៖ ហើយទៅណាក៏គេស្រឡាញ់ដែល។

ក៖ ចាសអ៊ុំ!

ខ៖ វាគ្មានស្អីទេគ្រាន់តែខ្វះញ៉ាំបន្តិច។ ហើយខ្ញុំជាំមនុស្សដែលគេស្រឡាញ់ហើយនឹងអាណិតមែននឹងហាស់៕

ក៖ ចាស! មែនតើអ៊ុំ។ ហើយអ៊ុំមើលទៅគួរអោយស្រឡាញ់មែនតើ។

ខ៖ ហាហាហា...!

ក៖ ចាស! ហើយនេះអ៊ុំកកើតមកសំណាងហើយដែលម្ដាយរបស់អ៊ុំបានផ្ដល់អោយ។ ហាហា..!

ខ៖ ហាហាចាស!

ក៖ ចាស! ហើយកុំអីត្រូបវេទនាដូចអ្នកដទៃដែលបាត់។

ខ៖ ហាហាចាស!

ក៖ មែនតើអ៊ុំកាលណឹងអ៊ុំអាំយុ១៧ឆ្នាំ។

ខ៖ ចាស!

ក៖ ហើយប៉ុន្តែគេគិតថាយើងនេះហាស់។

ខ៖ ចាស!

ក៖ គេអោយយើងនៅធ្វើការងារនឹង។

ខ៖ ចាស! នឹងហើយវាចឹងឯង៕

ក៖ អូ!!! អ៊ុំពិតជាសំណាងមែន។

ខ៖ ចាស!!

ក៖ អញ្ចឹងអ៊ុំកាលដែលអ៊ុំនៅរៀនហាស់? តើអ៊ុំបានរៀនដល់ថ្នាក់ទីប៉ុន្មានដែល???

ខ៖ នៅ កាលពីសង្គមនឹង, អ៊ុំរៀនបានដល់ថ្នាក់ទីប្រាំពីរ។

ក៖ ទីប្រាំពីរ!

ខ៖ ចាស! ទីប្រាំពីរចាសហាស់?

ក៖ ចាស! អញ្ចឹងស្មើនឹងថ្នាក់ទីមួយឬក៏ទីពីរ???

ខ៖ សព្វថ្ងៃនេះយើងទីមួយទីពីរទីបីទីបួនទីប្រាំ... ហើយចូលទីប្រាំមួយយើងឥឡូវនេះហើយ។

ក៖ ទីប្រាំមួយឥឡូវហ្ហអ៊ុំ???

ខ៖ ចាស! នឹងហើយទីប្រាំមួយឥឡូវ។

ក៖ ចាស!

ខ៖ ប្រឡងឌីប្លូម។ គេប្រឡងចប់...?

ក៖ ឌីប្លូមទីប្រាំមួយ???

ខ៖ ចាសនឹងហើយ! ឌីប្លូមទីប្រាំមួយ។

ក៖ អូ!! អញ្ចឹងអ៊ុំបានរៀនដល់ថ្នាក់ទីប្រាំមួយ???

ខ៖ ចាសនឹងហើយ!៕

ក៖ អញ្ចឹងអ៊ុំបានរៀននឹងអ៊ុំបានរៀននៅសម័យសង្គមឬក៏ម៉េច???

ខ៖ រៀនសម័យសង្គម!៕

ក៖ អូ!!! បន្ទាប់មកបានប៉ុលពតចូល???

ខ៖ ចាសនឹងហើយ! បន្ទាប់មកបានប៉ុលពតចូល។

ក៖ ចាស! អញ្ចឹងតើអ៊ុំអត់ចង់បន្តការសិក្សារបស់អ៊ុំទៀតទេហ្វបន្ទាប់ពីប៉ុលពតរួចហើយ???

ខ៖ គេចូលឡុន(គ្រាប់គ្នា) ប៉ុន្តែអ៊ុំអត់អ៊ុំអត់ចង់។

ក៖ ចាស!

ខ៖ កាលនឹងគេអោយចូលធ្វើជាំគ្រូអក្ខរកម្មដែលប៉ុន្តែអ៊ុំអត់ធ្វើ។

ក៖ ចាសអ៊ុំ!

ខ៖ រវល់នៅមើលក្មួយមើលអីនឹងហាស់។

ក៖ ចាសអ៊ុំ! អញ្ចឹងអ៊ុំអត់មានបំណងចង់រៀនទេអ៊ុំនេះ???

ខ៖ ចាស! អត់ អត់។

ក៖ ចាស! តើអ៊ុំស្តាយអត់ដល់ពេលចឹង???

ខ៖ ស្តាយ! អ៊ុំស្តាយដែលដល់ពៃលដែលឃើញពួកម៉ាកគេបានធ្វើការអីចឹងស្តាយដែល។

ក៖ ចាសអ៊ុំ!

ខ៖ រៀនជាមួយគ្នា, ចូលមកគេនាំគ្នាចូលរៀនទៅគេនាំគ្នាធ្វើគ្រូ។ ដល់ពេលយើងអត់ធ្វើអីនឹងគេ។ ប៉ុន្តែមិនស្តាយអីទេវាសនារបស់យើងបានគ្រួសារក៏វាសប្បាយដែល។

កះ ចាសអ៊ុំ! សប្បាយ,ហាហា..!

ខះ ហាហា.!នឹងហើយបានកូនអីទៅក៏វាធូរអស់ទៅ។ ខ្វិល។

កះ ចាសអ៊ុំ! អញ្ចឹងកាលអ៊ុំដូចថាអ៊ុំនៅពីក្មេងហាស់?

ខះ ចាស!

កះ ដូចថាក្មេងៗគាត់តែងតែនិយាយថាពេលធំឡើងចង់ធ្វើគ្រូ ចង់ធ្វើការនៅក្នុងធនាគារហើយនៅក្នុងម៉ាស៊ីនត្រជាក់ម៉ាស៊ីនអីចឹងហាស់អ៊ុំ??

ខះ ចាសនឹងហើយ។

កះ អញ្ចឹងសម្រាប់អ៊ុំវិញតើអ៊ុំចង់ធ្វើការងារអ្វីពេលដែលអ៊ុំធំដឹងក្ដីមក???

ខះ ពេលធំដឹងក្ដី??? ខ្ញុមចង់តែធ្វើតែគ្រូដែលតើ។

កះ អ្ហូ!! ហើពេលដែលគេអោយអ៊ុំធ្វើគ្រូអត់ធ្វើ???

ខះ ចាសអត់ធ្វើ៕

កះ ហេតុអ្វីអ៊ុំ???

ខះ វាររវល់រហូត!

កះ អ្ហូ!! រវល់។

ខះ មើលក្មួយនៅតែផ្ទះ។

កះ ចាស!

ខះ គ្មានអ្នកណាគេនៅមើលក្មួយ, ហើយបងៗពួកគាត់ទៅរកស៊ីអស់ហើយ។

កះ ចាស! អញ្ចឹងតើអ៊ុំស្ដាយដែលអត់ដែលថាអត់បានបំពេញនៅគោបំណាងរបស់ខ្លួនឯង។

ខះ ស្ដាយ, ស្ដាយមែនហើយល្មដែលថាទៅរួចនឹងគេ។

កៈ ចាសអ៊ុំ!

ខៈ ហើយអត់បានធ្វើ។

កៈ ចាសអត់អីតែអ៊ុំ។ កូនរបស់អ៊ុំបានធ្វើជំនួសអ៊ុំដែល។

ខៈ ចាសណឹងហើយគ្រូ។

កៈ ហា...! បំពេញបំណងរបស់ម្ដាយ។

ខៈ ចាសនឹងហើយបំពេញបំណង។

កៈ ចាស! ម្ដាយអត់បានធ្វើ, ប៉ុន្ដែកូនបានធ្វើ។

ខៈ ចាស!

កៈ អញ្ចឹងតាំងពីអ៊ុំដូចថាពេញវ័យមកហាស់អ៊ុំ។?

ខៈ ចាស!

កៈ តើអ៊ុំដូចថាបានធ្វើនូវការងារអ្វីខ្លះដែល???

ខៈ អ៊ុំដូចថាការងារចំម្ការ។

កៈ ចាស! ធ្វើតែស្រែចំការទេន៍អ៊ុំ???

ខៈ ចាសនឹងហើយ!ធ្វើតែស្រែចំការទេ។

កៈ ចាស! អញ្ចឹងឥឡូវនេះអ៊ុំមានស្រែច្រើនចំការច្រើដែលឬអត់???

ខៈ អត់ទៃអត់មានទេ! ស្រែមានមួយហិតា។

កៈ ទុកញាំ!

ខៈ នឹងហើយ! ហើយចំការទុកចែកកូនមួយៗម្នាក់នឹងឯង។

កៈ ចាស! ហើយនេះជាដីរបស់អ៊ុំទាំងអស់មែនទេ???

ខ៖ ចាសនឹងហើយ!

ក៖ អូ!! ដីរបស់អ៊ុំធំមែនទែនតាំងតែពីខាងមុខមក។

ខ៖ ចាសនឹងហើយតាំងពីខាងមុខមក។ ហើយផ្ទះខាងនោះមួយ, ផ្ទះកូនធ្វើផ្ទះថ្មធំមិញនឹងហូ??

ក៖ ចាស!អ៊ុំ។

ខ៖ ចាស! នឹងផ្ទះរបស់កូនធ្វើនៅទៅ។ មួយកន្លែងៗម្នាក់ទៅ។

ក៖ អូ!! នៅជិតៗគ្នាដែលស្រួយអ៊ុំ។

ខ៖ ចាសនឹងហើយ!

ក៖ អញ្ចឹងចំការរបស់អ៊ុំនេះតើអ៊ុំដាំអ្វីខ្លះ?? ខ្ញុំឃើញអ៊ុំមានដំណាំច្រើន។

ខ៖ មានត្របែក ក្រូច, ក្រូចឆ្មារ។

ក៖ ចាសអ៊ុំ! ដីនៅទីនេះដាំបានល្អហាស់។ អញ្ចឹងដោយសារតែគ្រុមគ្រួសាររបស់អ៊ុំហើយអ៊ុំធំដឹងក្តីឡើងធ្វើស្រែចំការចឹងហាស់??

ខ៖ ចាស!

ក៖ ចាស! ប៉ុន្តែជីវភាពរបស់គ្រុមគ្រួសាររបស់អ៊ុំគឺធូធារ??

ខ៖ ចាសនឹងហើយវាមិនអីទេ។

ក៖ ចាស! មានអ្វីញាំគ្រប់គ្រាន់។

ខ៖ ចាស!

ក៖ ចាស! ហើយបើសិនជាអ៊ុំប្រៀបធៀបពីជីវិតរបស់អ៊ុំពីមុខនឹងឥឡូវនេះហាស់តើវាខុសគ្នាឆ្ងាយដែលឬអត់???

ខ៖ ចាស! ខុស ខុស!

ក៖ ចាស!

ខ៖ ជីវិតសព្វថ្ងៃវាសប្បាយជាងពីមុខ។

ក៖ ចាសចាសអ៊ុំ!

ខ៖ ពីមុនម៉ែរបស់ខ្ញុំគាត់មានកូនច្រើនហាស់។

ក៖ ចាស!

ខ៖ ហើយគាត់រស់តែចិញ្ចឹមកូនច្រើន។ ហើយមកដល់ពេលសព្វថ្ងៃអ៊ុំមានគ្រួសារអ៊ុំមានតែកូនបីនាក់ទេ។

ក៖ ចាស!

ខ៖ អ៊ុំមានកូនតែបី, ហើយអ៊ុំធូធារជាង។ ហាហា...!

ក៖ ចាស! ហាហា....!

ខ៖ កូនធូធារនឹងមកពីកូនមានការងារ។

ក៖ ចាសអ៊ុំ!

ខ៖ កូនមានការងារធ្វើអស់ទៅសប្បាយចិត្ត។

ក៖ ចាសអ៊ុំ!

ខ៖ នឹងហើយ!

ក៖ ចាស! អញ្ចឹងអ្វីទៀតដែលអត់អ៊ុំ???

ខ៖ អត់មានទេមានតែប៉ុនណឹងឯង៕

ក៖ ខុសតែប៉ុនណឹងទេណ៎អ៊ុំ??

ខ៖ ចាស! ខុសតែប៉ុនណឹងទេ។

ក៖ ចាស! អញ្ចឹងពេលដែលអ៊ុំនៅពីក្មេងតើអ៊ុំចូលចិត្តញាំម្ហូបអ្វីជាងគេ???

ខ៖ ចូលចិត្តញាំហី???

ក៖ ចាសអ៊ុំ!

ខ៖ ចូលចិត្តញាំ សម្លរម្ជូរ។

ក៖ ចាស! ចាស់ៗចូលចិត្តញាំសម្លរម្ជូរគ្រប់គ្នា។

ខ៖ ចាសនឹងហើយ! ចង់ញាំតែសម្លរម្ជូរ។

ក៖ អញ្ចឹងអត់មានអ្វីក្រៅពីនឹងទៀតទេនៅអ៊ុំ??? មួយនឹងម្ហូបណោពីក្មេងដែឡអ៊ុំចូលចិត្ត???

ខ៖ ចាសនឹងហើយ! នៅពីក្មេង។ តែបើមលដល់សព្វថ្ងៃនេះបានតែដុតអាំងៗត្រីជ្រៀតអីចឹងទៅ។

ក៖ ចាស! ដូរហើយណ៍អ៊ុំ???

ខ៖ ចាសនឹងហើយ។

ក៖ ដូឬទៅជាត្រីដុតវិញម្តង។

ខ៖ នឹងហើយ ហាហា...!

ក៖ ហាហា...! ចុះម្ជូរម៉េចហើយអ៊ុំឈប់ចូលចិត្តហើយ???

ខ៖ ឈប់ហើយ! ញាំទៅវាច្រើនតែលើសឈាមលើសអីទៅអត់ទៅ។

ក៖ អ៊ូចាស!

ខ៖ ញាំតែត្រីៗ ហើយទៅពេទ្យគេអោយញាំតែត្រីៗទេ។

ក៖ ចាសអ៊ុំ!

ខ៖ ហើយអត់អោយញាំសាច់អីអត់ទេ។

ក៖ ចាស! ពេលខ្លះតើអ៊ុំឈ្លានចង់ញាំសាច់ដែលឬទេ??

ខ៖ ចង់ដែលតើ។

ក៖ តែអត់ហ៊ានណ៍អ៊ុំ???

ខ៖ ចាស! អត់ហ៊ានទេខ្លាច។

ក៖ ចាស!

ខ៖ ថៃសុខភាព។

ក៖ ចាស! អញ្ចឹងបន្ទាប់ពីម្ហូបហើយ ចំរៀង។

ខ៖ អ៊ូមិនចេះ! មិនចេះ៕

ក៖ តើអ៊ុំមានចំរៀងណាដែលថាអ៊ុំពេញចិត្តហើយអ៊ុំស្រឡាញ់ដែលឬទេ???

ខ៖ អ៊ូ!! ដៃឡពេញចិត្តហី???

ក៖ ចាសអ៊ុំ!

ខ៖ ហ៊ឺម..ចំរៀងមានស្អី! ចគរៀងសឹងស៊ីសាមុតពីដើមហ្ន៕

ក៖ ចាស! សឹងស៊ីសាមុតហីអ៊ុំ??

ខ៖ ចាស! ប៉ុននឹងឯង។ ហើយរស់សេរីឆ្នោធាអីចឹងទៅ។

ក៖ ចាស់ៗ គាត់ចូលចិត្តហើយនឹង។ ហាហា...!

ខ៖ ចាស! ហាហាហា...!!

ក៖ ចាស! ចុះមានចូលចិត្តបទចំរៀងសម័យដែលឬទេអ៊ុំ?? ដោយសារតែអ៊ុំនៅទាន់សម័យនេះចឹងហាស់ចាស??

ខ៖ អត់ទេ! សម័យនេះអត់ទេ, អត់ទេ។

ក៖ អត់ទេណ៍អ៊ុំ??

ខ៖ អត់ទេ។

ក៖ ចាស! អញ្ចឹងពេលអ៊ុំឮសូរបទចំរៀងសម័យក្មេងៗជំនាន់ពួកខ្ញុំច្រៀងតើអ៊ុំមានអារម្មណ៍យ៉ាងម៉េចដែល???

ខ៖ អ៊ុំអត់មានអ្វីទេ! ធម្មតាៗ។

ក៖ ធម្មតាៗន៏អ៊ុំ??

ខ៖ ចាស!

ក៖ តែបើអោយអ៊ុំចូលចិត្តអីអត់ចូលចិត្តទេ???

ខ៖ អត់ចូលចិត្តទេ។ តែធ្វើម៉េចបើគែស្តាប់ហើយចេះតែស្តាប់នឹងគេទៅ។

ក៖ ហាហា..!

ខ៖ ហើយបើគេមើលអីមើលនឹង នឹងគេទៅ។

ក៖ ចាសអ៊ុំ! នឹងហើយអ៊ុំ។ អញ្ចឹងដោយសារតែអ៊ុំបានប្រាប់ខ្ញុំថាផ្ទះរបស់អ៊ុំពីដើមធំមែនទេ???

ខ៖ អើ!

ក៖ ចាស! អញ្ចឹងផ្ទះនឹងឪពុកម្តាយរបស់អ៊ុំជាអ្នកសាងសង់ឬក៏គាត់ជួលគេ???

ខ៖ អើ! អត់ទេ។ អ៊ូ!! ជួលគេ៕

ក៖ ជួលគែហ្ស៎អ៊ុំ???

ខ៖ ចាសនឹងហើយ!

ក៖ ចាស! អញ្ចឹងពួកគាត់អត់មានអ្នកណាចេះសាងសង់ផ្ទះហើយធ្វើផ្ទះអីទេអត់ទេណ៍អ៊ុំ???

ខ៖ ចាស? អត់ទេ។

ក៖ អត់មានទេណ៍អ៊ុំ??

ខ៖ ចាសអត់មានទេជួលគេទាំងអស់។

ក៖ ចាស! អញ្ចឹងតើជីដូនជីតារបស់អ៊ុំហើយនឹងបងប្អូនរបស់អ៊ុំដែលតើមានអ្នកណាដែលថាពួកគាត់មានជំនាញធ្វើអ្វីមួយទេ???

ខ៖ ឪពុកម្ដាយរបស់ខ្ញុំហ្ស???

ក៖ ចាស!

ខ៖ ឪពុករបស់ខ្ញុំគាត់ចេះធ្វើតែស្រែនឹង។

ក៖ អូ! ជំនាញរបស់គាត់ធ្វើស្រែ??

ខ៖ ចាស! ឪពុករបស់ខ្ញុំគាត់ធ្វើតែស្រែនឹង។

ក៖ ចាស!

ខ៖ ហើយម្ដាយនៅផ្ទះមើលតែកូនទៅ។

ក៖ ចាស! អញ្ចឹងមកដល់អ៊ុំវិញតើអ៊ុំមានទេព្យកោសល្យអ្វីមួយផ្ទាល់ខ្លួនដែលឬទេដែលអាចរកលុយបានហាស់???

ខ៖ អ៊ុំសព្វថ្ងៃនេះហ្ស?? មានតែសាកដើមត្របែកហើយដើមក្រូចឆ្មារលក់ទៅ។

ក៖ ចាស! អញ្ចឹងខាងផ្នែកកសិកម្មវិញ។

ខ៖ ចាស! នឹងហើយ។ ខាងផ្នែកកសិកម្មនឹងហើយ។

ក៖ ចាស!

ខ៖ តែប៉ុនណឹង។

ក៖ ចាស! អញ្ចឹងតាំងពីដើមមកអ៊ុំធ្វើតែប៉ុនណឹងទេ??

ខ៖ ចាសតាំងពីដើមមកអ៊ុំហើយនឹងប្ដីរបស់អ៊ុំគាត់ធ្វើការទៅហើយអ៊ុំធ្វើតែប៉ុននឹងឯង។ ប្ដីអ៊ុំធ្វើការទៅ។

កៈ អ៊ូ!!!

ខៈ នៅផ្ទះហើយដាំបាយធ្វើអីតិចតួចអញ្ចឹងទៅគ្រាន់បានលក់។ តិចៗគ្រាន់បានដែល..!

កៈ ចាស! អញ្ចឹងអ៊ុំចេះខាងផ្សាំត្របែក?

ខៈ ចាសនឹងហើយ!

កៈ ជំនាញខាងនឹង! ពីឪពុកម្ដាយចែកអោយអ៊ុំឬក៏អ៊ុំដុងទៅខ្លួនឯង???

ខៈ ចាស! អ៊ុំដុងទៅខ្លួនឯង។

កៈ អ៊ូ!!

ខៈ ពុកម៉ែរបស់ខ្ញុំគ្មានចែកស្អីទេគាត់...! ចុះខ្ញុំនៅតូចដែរឡខ្ញុំគ្មានធ្វើអ្វី។

កៈ ចាសអ៊ុំ!

ខៈ ហាហា.!

កៈ អ៊ុំអត់បានរៀនអ្វីពីពួកគាត់ខ្លះទេ? អត់ទេណ៎អ៊ុំ??

ខៈ ចាស! អត់ទេ។

កៈ អញ្ចឹងអ៊ុំដុងខាងផ្នែកនឹង, អញ្ចឹងអ៊ុំអត់បានទៅរៀននកពីខាងណាទេណ៎អ៊ុំ???

ខៈ គ្មានទេ! ចេះខ្លួនឯង។

កៈ ចាស! ហើយដាក់ទៅចេះតែកើតហើយរស់ដែល???

ខៈ ចាសនឹងហើយ។

កៈ អ៊ូ!! អ៊ុំពិតជាខ្លាំងមែន...!!

ខៈ ចាស! ហាហា.!!

កៈ គេសុទតែទៅរៀនអស់លុយរាប់រយដុល្លាហាស់តែអ៊ុំទៅផ្សាំទៅសាកអីដោយខ្លួនឯង។

ខ៖ ចាសនឹងហើយ!៕

ក៖ ចាស! អញ្ចឹងតើអ៊ុំបានតើអ៊ុំបានចែកចំណេះដឹងមួយនឹងទៅដល់កូនចៅរបស់អ៊ុមដែលឬអត់???

ខ៖ កូនចៅចេះ៕

ក៖ ពួកគាត់ចេះគ្រប់គ្នាហីអ៊ុំ???

ខ៖ ចាស! ចេះគ្រប់គ្នា។

ក៖ ចាស! អញ្ចឹងល្អមែណទែន។

ខ៖ ចាស! នឹងហើយ។

ក៖ ចាស! អញ្ចឹងពេលដែលអស់ពីអ៊ុំទៅគាត់ចេះធ្វើបន្តទៀតហើយ។

ខ៖ ចាសនឹងហើយចេះធ្វើ។

ក៖ ចាស!

ខ៖ កាលដែលវាមិនទាន់បែក(មិនទាំនន់មានប្ដីមានប្រពន្ធ) គឺពួកាជួយធ្វើរហូតនឹងចំការ។ ជួយប៉េះល្មុតឥឡូវអ៊ុំកាប់ដើមល្មុតចោលអស់។ វាគ្មានផល។

ក៖ ចាសអ៊ុំ។

ខ៖ ល្មុតមានវាលក់មិនដាច់ដល់ពេលហើយទៅដាំត្របែកហើយនឹងក្រូចឆ្មារវិញទៅ។

ក៖ ចាស! អញ្ចឹងតើអ៊ុំបានចាប់ផ្ដើមដាំត្របែកហើយនឹងហាដើមក្រូចឆ្មារប៉ុន្មានឆ្នាំហើយអ៊ុំ???

ខ៖ បានបីឆ្នាំហើយ។

ក៖ អូ្វ!! អញ្ចឹងតើអ៊ុំចាប់ផ្ដើមទទួលប៉ុន្មានឆ្នាំហើយ???

ខ៖ អូ្វ!! បើថាត្របែកទទួលផល, ចង់បានដប់ឆ្នាំមកហើយ។ ដាំតាំងពីយ្រែបែកមូលរហូតដល់អាពូជក្រើមវិញហើយ។

កៈ អ្ហូ!! ចឹងនេះពូជគ្រើមវិញហ្ហអ៊ុំ???

ខៈ ចាស! គ្រើមវិញ។

កៈ ចាស! អាគ្រើមបានថ្លៃហាណាអ៊ុំ៕

ខៈ ចាសនឹងហើយអាគ្រើមបានថ្លៃ។

កៈ ចាសហើយឆ្ងាញ់ទៀត។ ហើយឥឡូវនេះតើមានផ្លែអត់អ៊ុំ???

ខៈ អ្ហូ!! ទឹមតែប៉េះហើយ, ម្សិលមិញ១៥គីឡូប៉ះអោយគែអស់។

កៈ អ្ហូចាស!

ខៈ មួយគីឡូបីពាន់គេមកយកអស់រលីង។

កៈ ចាស!

ខៈ ពីមុនអាមូល ដល់ពេលកាប់អាមូលចោលទៅដាំអាគ្រើមម្ដង។

កៈ ចាសអ៊ុំ! អញ្ចឹងពេលដែលអ៊ុំប៉េះវាម្ដងៗតើអ៊ុំប៉េះបានប៉ុន្មានគីឡូដែល??

ខៈ អ្ហូ! បើខែវស្សាវិញប៉ះម្ដងបាន៥០គីឡូ ៦០ អីទៅ។

កៈ បើគិតទៅគុណនឹងបីពាន់ទៅ! ហើយយកទៅអង្គុយលក់ខ្លួនឯងទៀតអាចបានថ្លៃលើសនឹងទៀតណ៎អ៊ុំ??

ខៈ ចាសនឹងហើយ!៕

កៈ ហាហា..!!! វាយ.. នេះចំណូលនៅផ្ទះផងហើយចំណូលបានមកពីកីនថៅទៀតមកផងមានអីក្រកើតនៃអ៊ុំ?។

ខៈ ហ៊ឹម..គ្រាន់តែបានមកមួទប់ទល់តែអូនអើយ។

កៈ ចាសនឹងហើយអ៊ុំ។ បានមួយរស់ស្រួយ។

ខៈ ចាសបានមួយរស់ស្រួយ។ នៅស្រួយបានកូនសព្វថ្ងៃនេះកូនចិញ្ចឹម។

កៈ ចាស!

ខៈ សព្វថ្ងៃនេះកូនមិនអោយខ្ញុំធ្វើទេ, សព្វថ្ងៃនេះហ្ន!!

កៈ ចាសអ៊ុំ!

ខៈ គេអោយម៉ែនៅស្ងៀមទៅហើយសំរានទៅលុយកាក់អីគេជាអ្នកចិញ្ចឹម។

កៈ ចាសអ៊ុំ!

ខៈ គេអោយម៉ែតែស្ងៀមទៅ តែម៉ែវានៅមិនស្ងៀម វាធ្លាប់។

កៈ ចាសអ៊ុំ! ប៉ុន្តែដាំចឹងទៅមើលទៅស្អាតទៀតធម្មជាតិហាស់អ៊ុំ។

ខៈ ចាសនឹងហើយ។

កៈ យើងបានទាំងលុយហើយយើងបានធម្មជាតិស្អាតទៀតហើយចាស...!

ខៈ ចាស!!

កៈ ចាស! (គាត់និយាយជាមួយកូនរបស់គាត់)។ នឹងអញ្ចឹងអ៊ុំតើពេលវេលាណាដែលអ៊ុំគិតថាពិបាកឆ្លងកាត់ជាងគេបំផុតនៅក្នុងជីវិតរបស់អ៊ុំ???

ខៈ លំបាកបំផុតមានពេលណាទេមានតែពេលដែលប្ដីស្លាប់នឹងឯង! ពិបាកជាងគេបង្អស់។

កៈ អូ្ហ! ប្ដីរបស់អ៊ុំគាត់ខូចហើយ???

ខៈ ចាសគាត់ស្លាប់ហើយនៅឆ្នាំ២០០០។

កៈ អូ្ហចាស!!

ខៈ ហើយនៅតែគ្រប់គ្រងកូនបីនាក់ហើយម៉ែមួយនឹង។

កៈ ចាស!

ខៈ លំបាកណាស់, លំបាកចិត្តនឹង។

កៈ ចាស! នឹងអញ្ចឹងអ៊ុំប្រុសបានខូចទៅអស់រយៈពេល១៩ឆ្នាំហើយ។ អ៊ូមិនមែនទេ..!

ខៈ ២០ឆ្នាំហើយ។

កៈ ចាសនឹងហើយ២០ឆ្នាំហើយ។

ខៈ ចាស ២០ឆ្នាំហើយ។

កៈ ខ្ញុំច្រឡំស្មានតែឆ្នាំនេះ២០១៩ហាហា។

ខៈ នឹងហើយ។

កៈ អញ្ចឹងតើពេលវេលាណាដែលអ៊ុំគិតថាសប្បាយរីករាយជាងគេបំផុតនៅក្នុងជីវិតរបស់អ៊ុំ???

ខៈ អ៊ូ!! មានពេលវេលាណាទេគឺជាពេលវេលានេះឯង។

កៈ ចាសហាហា..!!!

ខៈ ហាហាហ....!!!

កៈ ចាសនឹងហើយអ៊ុំ! អញ្ចឹងតើអ៊ុំសង្ឃឹមចង់បានអ្វីទៀតនៅថ្ងៃខាងមុខ???

ខៈ ហ៊ឹម..មិនសង្ឃឹមចង់បានអ្វីទេ។ សង្ឃឹមចង់អោយកូនរកស៊ីមានបានហើយម៉ែសប្បាយចិត្តហើយ។

កៈ ចាសអញ្ចឹង...! តើជុំមានអ្វីទៀតដែលអត់???

ខៈ អត់ទេកូន។

កៈ អត់ទែន៍អ៊ុំ?

ខៈ អត់មានអ្វីទេអស់ហើយអ៊ុំ។ ហាហា...!!!

កៈ អញ្ចឹងខ្ញុំក៏អស់អ្វីសួរដល់អ៊ុំដែលហើយ។ ហាហា...!!!

ខៈ ហាហា...!!!

កៈ ចាស! អញ្ចឹងខ្ញុំសូមអរគុណអ៊ុំច្រើនដែលហើយបានអោយខ្ញុំធ្វើការសម្ភាសអ៊ុំនៅថ្ងៃនេះ៕

ខៈ ចាសចាស!!

កៈ ចាស! អញ្ចឹងពីមុននឹងបញ្ចាប់ទៅតើខ្ញុំសូមធ្វើការថតរូបរបស់អ៊ុំមួយតើបានដែលឬទេ???

ខៈ ចាសបានថតទៅ។ ហាហា..!

កៈ ចាសអរគុណច្រើនអ៊ុំ៕